# លទ្ធផលនៃអំពើបាប The Results of Sin

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

**គោលការណ៍៖ យើងត្រូវការសេចក្តីសង្គ្រោះពី**

- ទោសនៃអំពើបាប
- អំណាចនៃអំពើបាបនិង
- វត្តមាននៃអំពើបាប

## *សេចក្តីផ្តើម* Introduction

លទ្ធផលរបស់បាបមានសភាពធ្ងន់ធ្ងរណាស់។ យើងមិនមានអ្វីដែលមានទំហំធំល្មមដើម្បីបង្ហាញពីផលប៉ះពាល់ដ៏ធំរបស់បាបបានទេ។ សូមស្រមៃមើលថាតើពិភពលោកនឹងមានទិដ្ឋភាពយ៉ាងណា ហើយមនុស្សយើងផង តើនឹងមានលក្ខណៈយ៉ាងណាប្រសិនបើគ្មានអំពើបាប ទន្ទ្រានចូលមកទេនោះ។ តែផ្ទុយទៅវិញបាបបានចូលមក ហើយធ្វើឱ្យមានផលប៉ះពាល់ច្រើនយ៉ាង ៖

## *ផលប៉ះពាល់ក្នុងទំនាក់ទំនងរវាងយើង និង ព្រះជាម្ចាស់* Results effecting our relationship with God

នៅក្នុងលោកុប្បត្តិ ជំពូក ៣ យើងឃើញថាអ័ដាម និងនាងអេវ៉ា មិនបានអរសប្បាយចំពោះព្រះវត្តមានរបស់ព្រះជាម្ចាស់ឡើយ ផ្ទុយទៅវិញ ពួកគេបានព្យាយាមគេចមុខពីព្រះអង្គ។ នេះគឺជាសោធនាដកម្មមួយដ៏គួរឱ្យរន្ធត់ ដ្បិតព្រះអង្គបានបង្កើតមនុស្សមកដើម្បីទទួលពរដ៏អស្ចារ្យពីទ្រង់ គឺជាអំណរចំពោះព្រះវត្តមានរបស់ទ្រង់ ប៉ុន្តែមនុស្សបែរជាគ្មានអំណរនេះសោះបន្ទាប់ពីការធ្លាក់ចុះក្នុងអំពើបាប។ ផ្ទុយពីការមានអំណរចំពោះព្រះវត្តមានព្រះ ពួកគេមានចិត្តភ័យខ្លាចចំពោះទ្រង់ព្រមទាំងពួនខ្លួនពីព្រះភក្ត្រទ្រង់ផង។ ឥឡូវនេះ ពេលដែលព្រះអង្គទតមកមនុស្ស ទ្រង់មិនសព្វព្រះទ័យសោះឡើយ ហើយទ្រង់ក៏នឹងនាំការជំនុំជំរះមកលើពួកគេផង។ មុនពេលធ្លាក់ចុះ អ័ដាម និងនាងអេវ៉ា អាចប្រកបទាក់ទងជាមួយព្រះអង្គដោយក្តីស្រឡាញ់ ដោយភាពជឿជាក់ ដោយទំនុកចិត្តនិងភាពស្និតស្នាល តែដល់ឥឡូវវិញសេចក្តីទាំងអស់នោះត្រូវបានជំនួសដោយភាពភ័យរន្ធត់និងការគេចវេសពីទ្រង់។ អ័ដាមនិងនាងអេវ៉ាបានត្រូវបណ្តេញចេញពីសួនច្បារអេដែន ការបណ្តេញចេញនេះបានបង្រៀនយើងច្រើនយ៉ាង ជាពិសេសបង្រៀនយើងឱ្យដឹងថា ពួកគេលែងបានរស់នៅក្នុងព្រះវត្តមានយ៉ាងពិសេសរបស់ទ្រង់ទៀតហើយ។

ដំណើរនេះប្រៀបដូចជា យើង និងប៉ូលីសដ៏ល្អម្នាក់ ប្រសិនបើយើងជាមនុស្សសុចរិតនោះយើងនឹងមិនមានការភ័យខ្លាចចំពោះប៉ូលីសទេ តែយើងនឹងមានចិត្តរីករាយវិញ ដ្បិតអីពេលមានប៉ូលីសដ៏ល្អនៅក្បែរ នោះនាំឱ្យយើងមានអារម្មណ៍ថាមានសុវត្ថភាព។ តែបើយើងជាឧក្រិដ្ឋជនវិញ នោះយើងមិនដែលមានចិត្តចង់ជួបមុខប៉ូលីសទេ។

- ❖ សូមអានព្រះគម្ពីរខាងក្រោមនេះតាមលំដាប់លំដោយ ព្រមទាំងសរសេរចុះនូវផលប៉ះពាល់របស់បាបក្នុងទំនាក់ទំនងរបស់យើងនឹងព្រះអង្គ។

លោកុប្បត្តិ ៣:៧-១០

និក្ខមនំ ៣២:១០-១១

ចោទិយកថា ៧:១០

ទំនុក. ៩៤:១

អេសាយ ១:២៣-២៤

ហូសេ ៩:១៥

ទំនុក. ៥:៥

សុភាសិត ៦:១៦-១៧

អេភេសូរ ២:៣

កូល៉ុស ១:២១

- មួយទៀត អំពើបាបនាំមនុស្សឱ្យមានទោសនៅចំពោះព្រះ ហើយមនុស្សក៏សមនឹងទទួលការជំនុំជំរះនេះដែរ។ ការដែលព្រះអង្គម្ចាស់ដាក់ទណ្ឌកម្មយើង នោះជារឿងមួយដ៏ត្រឹមត្រូវព្រោះយើងសមនឹងទទួលទណ្ឌកម្មនេះ។
- តើមានអ្វីកើតឡើងនៅពេលដែលគ្រីស្ទានធ្វើបាប? ប្រាកដជាមាន ទី១ វត្តមានរបស់យើងនៅចំពោះព្រះភក្ត្រទ្រង់នៅតែដដែល មិនមានអ្វីផ្លាស់ប្តូរទេ យើងនៅតែបានរាប់ជាសុចរិតនៅចំពោះវត្តមានទ្រង់ ដោយព្រោះព្រះគ្រីស្ទជាដង្វាយធួននិងបាបយើង។ ទី២ អំពើបាបនោះនាំឱ្យមានផលប៉ះពាល់ដល់ទំនាក់ទំនងរបស់យើងនឹងព្រះអង្គ។ ព្រះអង្គក៏មិនសព្វព្រះហឫទ័យចំពោះយើងទៀត ហើយទ្រង់ក៏នឹងដាក់ពិន័យយើងមិនខានឡើយ (អេភេសូរ ៤:៣០, វិវរណៈ ៣:១៩, ១ពេត្រុស ២:១១)។ ពេលយើងប្រព្រឹត្តបាបព្រះអង្គនៅតែរាប់យើងជាមនុស្សសុចរិតនៅក្នុងព្រះគ្រីស្ទ ប៉ុន្តែយើងនឹងបាត់បង់រង្វាន់នៅឯនគរស្ថានសួគ៌ (២កូរិនថូស ៥:១០, ម៉ាថាយ ៥:១២)។

## ការយល់ឃើញផ្សេងៗទាក់ទងនឹងការដាក់ទណ្ឌកម្ម

នៅពេលដែលយើងនិយាយពីការដាក់ទណ្ឌកម្មយើងត្រូវគិតពីការណ៍២យ៉ាងជាសំខាន់។ ការណ៍ទី១, យើងត្រូវគិតដល់គោលបំណងរបស់ទ្រង់ក្នុងការដាក់ទណ្ឌកម្មនេះ ហើយទី២ យើងត្រូវគិតពីភាពខុសគ្នារវាងការដាក់ទណ្ឌកម្មរបស់ព្រះអាទិករដ៏មានគ្រប់ព្រះចេស្តាជាមួយនិងទ្រឹស្តីកម្មផល (*Karma*) ដែលបានបង្រៀនថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។

### គោលបំណងរបស់ព្រះអម្ចាស់យេហូវ៉ាក្នុងការដាក់ទណ្ឌកម្ម

យើងត្រូវសួរសំនួរពីគោលបំណងរបស់ព្រះអង្គ ក្នុងការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តបាប ថាតើការដាក់ទណ្ឌកម្មរបស់ទ្រង់ដើម្បីជាការកែតម្រង់ ជាការរារាំង ឬក៏ជាការបំផ្លាញបង់។ ពេលដែលយើងនិយាយពីការដាក់ទណ្ឌកម្មរបស់ព្រះ ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា *មានទាំង៣យ៉ាងគឺ មានទាំងការកែទំរង់ ការរារាំង, និងក៏មានលក្ខណៈជាការបំផ្លាញបង់ដែរ* (ទំនុក. ៩៤:១, អេសាយ ១:២៤, ៦១:២, ៦៣:៤, យេរេមា ៤៦:១០, អេសេគាល ២៥:១៤, រ៉ូម ១២:១៩)។ អ្នកខ្លះគិតថា ការដាក់ទណ្ឌកម្មបែបបំផ្លាញនេះមានលក្ខណៈផ្ទុយស្រឡះពីសេចក្តីបង្រៀនដែលថា ព្រះអង្គជាតួនៃសេចក្តីស្រឡាញ់ ប៉ុន្តែគំនិតបែបនេះមិនត្រឹមត្រូវទេ។ ការដាក់ទណ្ឌកម្មបែបបំផ្លាញ (ដាក់ទោស) (*retributive punishment*) ក៏យើងធ្លាប់បានមើលឃើញព្រឹត្តិការនេះហើយដែរ ដូចការដែលទ្រង់បានបំផ្លាញក្រុងសូដុំមនិងកូម៉ូរ៉ា។

ក្រិត្យច្បាប់ជាច្រើនដែលព្រះអង្គបានប្រទាននៅគ្រាសញ្ញាចាស់បញ្ជាក់យ៉ាងច្បាស់ថា ទ្រង់ប្រទានមកសំរាប់រារាំងដល់ពួកអ៊ីស្រាអែលឱ្យចៀសចេញពីឧក្រិដ្ឋកម្ម (ចោរទិ. ៦:១២-១៥, ៨:១១, ១៩-២០)។ ឯពួកហោរាវិញក៏បានថ្លែងព្រះបន្ទូលរារាំងពួកគេពីការជំនុំជំរះរបស់ព្រះអង្គដែរ (យេរេមា ៧:១២-១៤, អេសេគាល ១៨)។ ជួនកាលការដាក់ទណ្ឌកម្មរបស់ទ្រង់មានទ្រង់ទ្រាយទាំងពីរយ៉ាងគឺមានទាំងការរារាំងនិងការបំផ្លាញបង់ផង។ ដោយហេតុនេះហើយបានជាការដាក់ទណ្ឌកម្មខ្លះបានធ្វើឡើងនៅទីសាធារណៈ ដូចជាក្នុងករណីការដាក់ទណ្ឌកម្មដោយចោលសំឡាប់នឹងថ្មដល់អេកាននិងគ្រួសាររបស់គាត់នៅព្រះគម្ពីរយ៉ូស្វេ ៧។

ការដាក់ទណ្ឌកម្មរបស់ព្រះយេហូវ៉ាដែលមានទ្រង់ទ្រាយជាការកែទំរង់ដល់ពួកអ៊ីស្រាអែល មានចែងទុកនៅក្នុងព្រះគម្ពីរទំនុកដំកើង ១០៧:១០-១៦។ ព្រះគម្ពីរនេះបានប្រាប់ពីគ្រាមួយពេលដែលពួកអ៊ីស្រាអែលបានវិលមកអំពាវនាវរកព្រះអង្គម្ចាស់វិញ នៅពេលដែលពួកគេបានទទួលទណ្ឌកម្មរបស់ព្រះអង្គ។ នៅក្នុងព្រះគម្ពីរអេម៉ុស ៤ ព្រះយេហូវ៉ាបានប្រទានការសោកសង្រេងមួយដល់ពួកអ៊ីស្រាអែល ដោយសង្ឃឹមថាពួកគេនឹងធ្វើការប្រែចិត្តមករកព្រះអង្គវិញ ប៉ុន្តែពួកគេនៅតែចចេសមិនព្រមប្រែចិត្តសោះ។ នៅក្នុងព្រះគម្ពីរទំនុកដំកើង ១១៩:៧១ អ្នកនិពន្ធបានមានប្រសាសន៍ថា ការដែលគាត់កើតមានទុក្ខព្រួយនោះ ជាប្រយោជន៍ដល់គាត់ហើយ ដើម្បីឱ្យគាត់បានរៀនយកបញ្ញត្តរបស់ទ្រង់។

**ភាពខុសគ្នារវាងទណ្ឌកម្មរបស់ព្រះយេហូវ៉ានិងទស្សនកម្មផល**

នៅទីនេះមានសេចក្តីបង្រៀនច្រើនយ៉ាងទៀតដែលយើងអាចយកទៅបង្រៀនបាន។ ដំបូងយើងអាចលើកយកពីអង្គព្រះយេហូវ៉ាដែលជាអង្គអាទិករ ជាអង្គដែលមានអំណាចគ្រប់គ្រង់លើគ្រប់ទាំងអស់ ហើយក៏ជាអង្គបានកំណត់យ៉ាងច្បាស់ថា អ្វីជាខុស អ្វីជាត្រូវ ព្រមទាំងមានសិទ្ធិលើគ្រប់ទាំងអស់ ក្នុងការដាក់ទណ្ឌកម្ម ឬក៏ជាការប្រទានរង្វាន់។ ហើយគ្រប់ការទាំងនេះព្រះអង្គក៏មិនបានប្រើប្រព័ន្ធមេកានិចក្នុងការចាត់ចែងដែរ។ ព្រះអង្គមិនមានប្រព័ន្ធអ្វីផ្សេងក្នុងការគ្រាប់តាមដែរ គឺទ្រង់មានចេស្តាក្នុងការធ្វើកិច្ចការនេះ។ ប្រសិនបើទ្រង់ចង់សំដែងសេចក្តីសប្បុរសនោះទ្រង់ក៏សំដែងតាមព្រះហឫទ័យ, ហើយបើទ្រង់ចង់ជំនុំជំរះ នោះទ្រង់ក៏ជំនុំជំរះតាមព្រះហឫទ័យដែរ នេះគឺស្រេចនឹងព្រះហឫទ័យរបស់ព្រះអង្គ។

ម្យ៉ាងទៀតព្រះគម្ពីរបង្រៀនថា មនុស្សយើងមានជីវិតតែមួយ បន្ទាប់ពីស្លាប់ទៅយើងនឹងប្រឈមមុខចំពោះការជំនុំជំរះ (ហេព្រើរ ៩: ២៧)។ យើងគ្មានការចាប់ជាតិ ហើយបន្តផលកម្មពីជាតិមុនទៀតនោះទេ។ លទ្ធផលនៃអំពើបាបមិនមែននាំយើងឱ្យទៅទទួលរងនូវផលដែលបានសាងពីជាតិមុននោះទេ តែវានឹងនាំយើងឱ្យទៅប្រឈមមុខចំពោះការជំនុំជំរះរបស់ព្រះដ៏នៅអស់កល្បជានិច្ចវិញ។ (មនុស្សមានបាប លទ្ធផលគឺជា សេចក្តីស្លាប់)

## សំនួរ

តើអ្វីទៅជា**គោលបំណងរបស់ព្រះអម្ចាស់យេហូវ៉ាក្នុងការដាក់ទណ្ឌកម្ម?**

**តើទណ្ឌកម្មរបស់ព្រះយេហូវ៉ានិងទស្សនកម្មផល**មានការខុសគ្នាអ្វីខ្លះ?

## *លទ្ធផលរបស់បាបចំពោះមនុស្សមានបាប* Effects on the Sinner

- **សេចក្តីស្លាប់៖** លទ្ធផលដំបូងនៃអំពើបាបគឺជាសេចក្តីស្លាប់ (លោកុប្បត្តិ ២:១៧, ៣:២២, រ៉ូម ៥:១២, ៦:២៣)។ មុនអ័ដាម និងអេវ៉ាបានប្រព្រឹត្តបាប វាហាក់ដូចជាពួកគេមានលទ្ធភាពក្នុងដំណើរជីវិតគឺអាចស្លាប់ឬរស់នៅអស់កល្បជានិច្ច។ ប៉ុន្តែក្រោយពេលពួកគេបានប្រព្រឹត្តអំពើបាបពួកគេត្រូវតែស្លាប់។ នៅក្នុងព្រះគម្ពីរ សេចក្តីស្លាប់មានច្រើនយ៉ាងគឺមានសេចក្តីស្លាប់ខាងសាច់ឈាម, សេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណនិងសេចក្តីស្លាប់អស់កល្បជានិច្ច។ សេចក្តីស្លាប់ទាំងនេះមានទំនាក់ទំនងរវាងគ្នានិងគ្នា។
- **ភាពដូចជារូបអង្គទ្រង់នៅក្នុងខ្លួនមនុស្សត្រូវខូចបង់៖** យើងដឹងហើយថា បន្ទាប់ពីមនុស្សបានធ្លាក់ចុះ ភាពដូចជាអង្គទ្រង់នៅតែមានក្នុងខ្លួនមនុស្សដដែល ប៉ុន្តែវាបានខូចបង់អស់ហើយ។
- **ព្រះជាម្ចាស់ហាមមិនអោយមនុស្សបរិភោគផ្លែឈើពីដើមនៃជីវិត និងការបណ្តេញចេញពីសួនអេដែន៖ (ត្រង់នេះវាទាក់ទងនិង** ចំនុចទី១គឺសេចក្តីស្លាប់)។ ព្រះយេស៊ូវបានយកជ័យលើអំពើបាប និងឥទ្ធិពលរបស់វាទាំងអស់។ ដូច្នេះនៅក្នុងព្រះគម្ពីរវិវរណៈ (វិវរណៈ ២:៧, ២២:២,១៤,១៩)បានបង្ហាញថាព្រះគ្រីស្ទបានយកឈ្នះលើឥទ្ធិពលរបស់បាបនេះ។
- **ភាពខ្មាសអៀន៖ ពេលដែលអ័ដាមនិងអេវ៉ាធ្វើបាបពួកគេចាប់ផ្តើមមានអារម្មណ៍អៀនខ្មាស** (លោកុប្បត្តិ ៣:៧)។ មុនពេលធ្លាក់ចុះ ពួកគេមិនមានសេចក្តីខ្មាសចំពោះភាពអាក្រាតទេ (លោកុប្បត្តិ ២:២៥)។ នេះមិន

មែនមានន័យថា បើគេនៅអាក្រាត តែមិនខ្មាស នោះគេជាមនុស្សមានបាបហើយ។ តែព្រះគម្ពីរបង្រៀនថា មុនពេលធ្លាក់ចុះ មនុស្សរស់នៅដោយគ្មានការខ្មាសអៀនអ្វីទាំងអស់ ទោះជារស់នៅក្នុងភាពអាក្រាតក៏ដោយ។ ប៉ុន្តែក្រោយពីការធ្លាក់ចុះគ្រប់យ៉ាងបានផ្លាស់ប្តូរទាំងស្រុង។

- **ស្ថិតក្រោមទាសភាព៖ តាមរយៈខព្រះគម្ពីរខាងក្រោម តើបាបបានគ្រប់គ្រងយើងដូចម្តេចខ្លះ?**

យ៉ូហាន ៨:៣៤

រ៉ូម ៦:១៧

រ៉ូម ៧:១៤-២០

ទីតុស ៣:៣

- **មិនទទួលខុសត្រូវ៖** ***អ័ដាមបន្ទោសទៅនាងអេវ៉ា នាងអេវ៉ាស្តីបន្ទោសឱ្យសត្វពស់***

(លោកុប្បត្តិ ៣:១២-១៣)។ សព្វថ្ងៃមនុស្សតែងតែប្រើវិធីសាស្ត្របែបនេះដែរ។

- **បោកបញ្ឆោតខ្លួនឯង៖** ***យេរេមា ១៧:៩ មនុស្សមានចិត្តមិនទទួលស្គាល់នូវការពិតអំពីខ្លួនឯង។*** យើង

តែងតែមើលឃើញពីអំពើបាបរបស់អ្នកដទៃ តែមិនសូវមើលឃើញអំពើបាបរបស់ខ្លួនឯងទេ (ម៉ាថាយ ៧:១-៥)។ ដូចជាក្នុងករណីដាវីឌ អំពើបាបរបស់ខ្លួន គាត់មើលមិនឃើញទេ ប៉ុន្តែអាចមើលនៅក្នុងជីវិតរបស់អ្នកមានម្នាក់នៅក្នុងរឿងប្រៀប ធៀបរបស់ហោរាណាថាន់។ តាមពិត ក្រោយពេលបានស្តាប់រឿងប្រៀបធៀបរបស់ហោរាណាថាន់ចប់ ដាវីឌក៏មិនទាន់ដឹងថា ហោរាណាថាន់ចង់និយាយបញ្ចិតបញ្ចៀងឱ្យលោកដែរ រហូតដល់ហោរាណាថាន់និយាយចំៗតែម្តង។

- **គ្មានការពិចារណា៖** ***ពេលដែលមនុស្សនៅតែបន្តរស់នៅក្នុងបាបហើយបដិសេធន៍ចោលការព្រមានរបស់ព្រះ*** នោះសតិសម្បជញ្ញៈរបស់គេបានបណ្តោយឱ្យពួកគេប្រព្រឹត្តអ្វីៗតាមតែអំពើចិត្ត (រ៉ូម ១:២៨-៣២, អេភេសូរ ៤:១៧-១៩)។
- **មនុស្សមានប្រាជ្ញាដ៏ឥតប្រយោជន៍ និងគំនិតងងឹតសូន្យសុង** (អេភេសូរ ៤:១៧-១៩)
- **បញ្ហាខាងរាងកាយនិងចិត្តគំនិត** ឧទាហរណ៍ ជាញឹកញាប់មនុស្សមានជំងឺ មានចិត្តក្រៀមក្រំធុញថប់ដែលកើតមកពីខឹងនិងអ្នកដទៃ ហើយខ្វះសមត្ថភាពក្នុងការអត់ទោសឱ្យគេ នេះជាផលនៃអំពើបាប ប៉ុន្តែវាក៏មិនមែនជាលទ្ធិផលនៃអំពើបាបទាំងស្រុងនោះដែរ។
- **ការខកចិត្តនិងភាពមិនស្កប់ស្កល់ បាបនាំឱ្យមនុស្សមិនចេះស្កប់ចិត្ត។** ផលដំបូងដែលអ័ដាមនិងអេវ៉ាបាន

ទទួលក្រោយការដែលគាត់ធ្លាក់ចុះគឺពួកគាត់ខកចិត្ត ពួកគេធ្លាប់គិតថា បន្ទាប់ពីបរិភោគផ្លែឈើពីដើមឈើដែលទ្រង់ហាមនោះហើយពួកគេអាចកែប្រែស្ថានភាពរស់នៅ ដោយពួកគេអាចក្លាយដូចជាព្រះ ប៉ុន្តែពួកគេបែរជាទទួលបាននូវសេចក្តីអៀនខ្មាសទៅវិញ។

## *ផលប៉ះពាល់រវាងមនុស្សនិងមនុស្សនិងក្នុងសង្គម* Effects on the Relationship to Other Humans and Society

- **ការប្រកួតប្រជែងគ្នា៖** ***យើងគួរប្រើអំណោយទានក្នុងការជួយដល់អ្នកឯទៀត តែផ្ទុយទៅវិញយើងប្រើវា ដើម្បីនឹងអួតបំប៉ោងដល់អ្នកឯទៀត ហើយដើម្បីប្រកួតប្រជែងនិងអ្នកដទៃទៀតវិញ។*** ភាពអាត្មានិយមមានច្រើនឡើងប៉ុណ្ណានោះ ការប្រកួតប្រជែងនិងជំលោះក៏រឹតតែកើនឡើងប៉ុណ្ណោះដែរ។ ឧទាហរណ៍ មានមនុស្ស ជាច្រើនដែលអាចចង់បានផ្ទះតែ១ដូចគ្នា អាច ស្រឡាញ់មនុស្សប្រុស ស្រីតែម្នាក់ដូចគ្នា។ ស្ថានភាពនេះអាចបង្កើតឱ្យមានអ្នកឈ្នះនិងអ្នកចាញ់។ ហើយពេលដែលដឹងឈ្នះចាញ់ ហើយ អ្នកឈ្នះអាចនៅមិនស្ងប់ដែរ ព្រោះខ្លាចអ្នកចាញ់នោះមិនសុខចិត្តហើយក៏ធ្វើអំពើអ្វីមួយមកលើខ្លួន។ អ្នកចាញ់អាច មិនសុខចិត្ត ក៏មាន

ចិត្តច្រណែនចំពោះអ្នកឈ្នះ។ ដូច្នេះទាំងអ្នកចាញ់ ទាំងអ្នកឈ្នះ គ្មានអ្នកណាមួយអាចចៀស ផុតពីផលអវិជ្ជមាននៃអំពើបាប បានឡើយ។

- **ខ្វះសមត្ថភាពក្នុងការចែកចាយ ដាក់ទានៈ ភីលីព ២:៣-៥**
- **ការឈ្លោះប្រកែកនិងការកាប់សំឡាប់គ្នា៖ យ៉ាកុប ៤:១-៣, ១កូរិនថូស ៣:២-៣**
- **មិនចុះចូលនិងរដ្ឋអំណាច ការបែកបាក់គ្នា**
- **អំពើហិង្សាក្នុងគ្រួសារ និងការលែងលះគ្នា**
- **ជំងឺទូទៅកើតមាននៅក្នុងសង្គម, ឧ. ការរីករាលដាលនៃជំងឺអេដស៍**
- **ការជិះជាន់, កេងប្រវ័ញ្ច**

## *ផលប៉ះពាល់ដល់បរិស្ថាន* Effects on the Environment

- **ផលប៉ះពាល់ជាទូទៅ៖** លោកុប្បត្តិ ៣:១៧ បង្ហាញថាដីត្រូវបណ្តាសាគឺជាផ្នែកមួយនៃការដាក់ទណ្ឌកម្មរបស់ព្រះដល់មនុស្ស។ម្យ៉ាងទៀតរបស់សព្វសារពើបានខូចបង់ ពុកផុយក៏ដោយសាតែអំពើបាបដែរ (រ៉ូម ៨:២០-២១)។

**ផលនៃអំពើបាបបានប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថានរួមមាន៖**

- **ផ្ទៃដីត្រូវបំផ្លាញ ដីបាត់បង់នូវជីជាតិសំរាប់ដំណាំចំការ**
- **ការកាប់បំផ្លាញព្រៃឈើ**ដែលជាឧទាហរណ៍មួយបញ្ជាក់យ៉ាងច្បាស់ថា អំពើបាប(ការលោភលន់និងការជិះជាន់កេងប្រវ័ញ្ច) នាំឱ្យមានការបំផ្លាញបរិស្ថាន។

អ្នកខ្លះ បានស្តីបន្ទោសដល់សេចក្តីជំនឿរបស់គ្រីស្ទានពីព្រោះតែបរិស្ថានត្រូវបំផ្លាញ។ ពួកគេនិយាយថាដោយសាព្រះគម្ពីរបង្រៀនដល់មនុស្សនៅភាគខាងលិចថា មនុស្សជាអ្នកគ្រប់គ្រងលើផែនដី (លោកុប្បត្តិ ១) ដូច្នេះហើយបានជាមនុស្សនាំគ្នាធ្វើការបំផ្លាញបរិស្ថានយ៉ាងនេះ។ តែការចោទប្រកាន់នេះមិនត្រឹមត្រូវទេ។ ពួកគ្រីស្ទានបានបង្រៀនថា ព្រះគម្ពីរបង្រៀនថាមនុស្សជាអ្នកគ្រប់គ្រងផែនដី ដូច្នេះមនុស្សត្រូវតែទទួលខុសត្រូវក្នុងការមើលថែរក្សាផែនដី។ ហើយព្រះគម្ពីរ លោកុប្បត្តិ ២:១៥ ក៏បញ្ជាក់យ៉ាងច្បាស់ថា ព្រះយេហូវ៉ាទ្រង់បានត្រាស់បង្គាប់ដល់មនុស្សឱ្យមើលថែផែនដី។ នេះជាការត្រាស់បង្គាប់របស់ព្រះជាម្ចាស់ ហើយមនុស្សក៏ត្រូវមានការទទួលខុសត្រូវទាំងស្រុង។ ការធ្វើអាជីវកម្មដីធ្លីមិនមែនជាកំហុសរបស់ព្រះគម្ពីរនោះទេ តែវាជានិស្ស័យបាបរបស់មនុស្សវិញដែលធ្វើការនេះ។ ដូច្នេះ ព្រះបន្ទូលរបស់ព្រះ មិនមែនជាបញ្ហាទេ តែជាដំណោះស្រាយដ៏ប្រសើរវិញ ព្រោះគម្ពីរបានថ្លែងប្រកាសថា ព្រះបន្ទូលរបស់ព្រះនឹងនាំមនុស្សឱ្យរួចពីបាប ហើយវិលបែរមកឯព្រះវិញ ដែលការវិលនេះនឹងនាំឱ្យមានលទ្ធផលជាវិជ្ជាមានដល់បរិស្ថាន។ ម្យ៉ាងទៀតព្រះគម្ពីរក៏បានព្រមានហើយថា ព្រះនឹងជំនុំជំរះគ្រប់អំពើបាបទាំងអស់ ដែលការទាំងនេះ នឹងកំឡាចិត្តមនុស្សឱ្យលែងមានចិត្តអាត្មានិយមទៀត។

## *សេចក្តីសង្គ្រោះ* Salvation

នៅដើមដំបូងនៃមេរៀននេះយើងបានរៀនថា យើងត្រូវការសេចក្តីសង្គ្រោះពីទោសនៃអំពើបាប អំណាចនៃអំពើបាបនិងវត្តមាននៃអំពើបាប។ ដំណឹងល្អបានប្រកាសថា ព្រះគ្រីស្ទបានសង្គ្រោះយើងពីទោសនៃអំពើបាបរួចទៅហើយ បច្ចុប្បន្ននេះកំពុងតែសង្គ្រោះយើងពីអំណាចនៃអំពើបាប ហើយនៅក្នុងពេលអនាគតទ្រង់នឹងសង្គ្រោះយើងពីវត្តមាននៃអំពើបាប។